# មជ្ឈមណ្ឌលឯកសារកម្ពុជា

ប៉ាក សុខ ភេទប្រុស (រស់)

តួនាទីៈ "យោធាជើងទឹក កងពល១៦៤"

សម្ភាសន៍ជាមួយឈ្មោះប៉ាក សុខ អាយុ៤៥ឆ្នាំ

រស់នៅភូមិដំណាក់សុក្រម ឃុំស្នាយអញ្ជិត ស្រុកជំគីរី ខេត្តកំពត ។

ថ្ងៃទី២៥ខែមេសា ឆ្នាំ២០០៧

សម្ភាសន៍ដោយៈ ឡុង ដានី

សរុបៈ ២៣ទំព័រ

ដានីៈ ចឹងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

សុខៈ ប៉ាក សុខ ។

ដានីៈ ចឹងពូអាយុប៉ុន្មានហើយ?

សុខៈ អាយុ៤៥ ។

ដានីៈ ចឹងពូកើតឆ្នាំអី ឆ្នាំខ្មែរ?

សុខៈ កើតឆ្នាំរកា ។

ដានីៈ សព្វថ្ងៃពូរស់នៅក្នុងភូមិឃុំអីដែរ?

សុខៈ សព្វថ្ងៃរស់នៅភូមិដំណាក់សុក្រម ឃុំស្នាយអញ្ជិត ស្រុកជំគីរី ខេត្តកំពត ។

ដានីៈ ស្រុកកំណើតពូនៅហ្នឹងដែរ.?

សុខៈ បាទ ។

ដានីៈ គ្រួសារពូឈ្មោះអីដែរ?

សុខៈ ឈ្មោះ ភាព ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

សុខៈ គាត់កើតឆ្នាំកុល ។

ដានីៈ ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់?

សុខៈ មាន៨នាក់ ។

ដានី៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

សុខ៖ ស្រី៣ប្រុស៥ ។

ដានី៖ ពូចូលធ្វើកងទ័ពតាំងពីកាល?

សុខ៖ ចូលតាំងពីឆ្នាំ៧២ ។

ដានី៖ កាលហ្នឹងពូស្ម័គ្រចិត្តចូលឬយ៉ាងម៉េច?

សុខ៖ បាទ កាលហ្នឹងស្ម័គ្រចិត្តចូល ។

ដានី៖ យ៉ាងម៉េចបានជាពូស្ម័គ្រចិត្តចូល?

សុខ៖ កាលហ្នឹងដោយសារមានកំហឹងឈឺចាប់ចំពោះខ្មាំងដែលវាធ្វើបាបឪពុកម្ដាយពេកណាស់ ។

ដានី៖ ខ្មាំងខាងលន់ នល់?

សុខ៖ ខ្មាំងខាងលន់ នល់ ។

ដានី៖ ចឹងកាលពូចូលដំបូងនៅខាងណាទៅ?

សុខ៖ ចូលដំបូងនៅខាងកងទ័ពតំបន់ ។

ដានី៖ តំបន់ណា?

សុខ៖ ខេត្តកំពត ។

ដានី៖ កាលហ្នឹងពីណាគេជាមេបញ្ជាការ?

សុខ៖ កាលហ្នឹង តា ចាប កាលហ្នឹងគាត់ជាគណៈតំបន់ ។

ដានី៖ ចឹងកាលហ្នឹងគណៈតំបន់គាត់ទទួលខាងកងទ័ពដែរ?

សុខ៖ បាទ ។

ដានី៖ ចឹងពូធ្វើនៅហ្នឹងបានរយៈពេលប៉ុន្មានដែរ?

សុខ៖ ខ្ញុំចូលនៅទ័ពតំបន់ហ្នឹងបានបីឆ្នាំ ។

ដានី៖ ចឹងបីឆ្នាំ៧៥ ហើយបានឡើងភូមិភាគ?

សុខ៖ អត់ទេ ឡើងឆ្នាំ៧៣ មើល៧១-៧២-៧៣-៧៤បានឡើងភូមិភាគ ។

ដានី៖ ចឹងកាលហ្នឹងពូនៅក្នុងកងពលអីគេ?

សុខ៖ កងពលទី៣ ។

ដានី៖ ចឹងកាលហ្នឹងប្រធានកងពលពីណាគេ?

សុខ៖ កាលជំនាន់ហ្នឹងមានតា សារឿន ។

ដានី៖ តា សារឿនហ្នឹងគាត់ជាអ្នកស្រុកណា?

សុខ៖ គាត់នៅខាងខេត្តកំពង់ស្ពឺ ។

ដានី៖ គាត់ តា០៥ឬ០៦?

សុខ៖ គាត់តា០៥ ។

ដានី៖ ចឹងកាលជំនាន់ហ្នឹងគេហៅគាត់តា ០៥ដែរ?

សុខ៖ នៅទេ ។

ដានី៖ ពូនៅហ្នឹងបានរយៈពេលប៉ុន្មាន?

សុខ៖ ខ្ញុំនៅទ័ពហ្នឹងបានរយៈពេលមួយឆ្នាំ ។

ដានី៖ ចឹងដល់ឆ្នាំ៧៥បែកភ្នំពេញហើយគេឲ្យពូទៅណាទៀត?

សុខ៖ បែកភ្នំពេញហើយអង្គការចាត់តាំងឲ្យទៅកំពង់សោម ។

ដានី៖ គេឲ្យទៅនៅកំពង់សោមហ្នឹង គេឲ្យទៅនៅកន្លែងណា?

សុខ៖ កាលហ្នឹងគេចាត់តាំងឲ្យទៅនៅរៀម ទៅដល់រៀមខ្ញុំឡើងកប៉ាល់ទៅនៅលើកោះ ។

ដានី៖ ចឹងដល់ទៅនៅកំពង់សោមនៅក្នុងកងពលណាទៅ?

សុខ៖ នៅកងពល១៦៤ ។

ដានី៖ ចឹងប្រធានកងពលពីណាគេ?

សុខ៖ តា មុត ។

ដានី៖ ចឹងតា មុតកាលមុនបែក៧៥គាត់ទៅនៅណា?

សុខ៖ មុនបែក៧៥គាត់នៅកងពលធំ កងពលទី៣ហ្នឹងតែម្តង ។

ដានី៖ ជាមួយតា សារឿនហ្នឹងដែរ?

សុខ៖ បាទ ។

ដានី៖ ចឹងគាត់ធំជាតា សារឿនឬតូចជាងតា សារឿន.?

សុខ៖ តា សារឿនធំជាងគេតែម្តង គាត់ជាប្រធានកងពលតែម្តង ។

ដានី៖ ចឹង តា មុតគាត់នៅកងពលទី៣ហ្នឹងដែរ?

សុខៈ គាត់នៅហ្នឹង គាត់ទទួលរួមតែម្តង ។

ដានីៈ នៅណា?

សុខៈ នៅខាងកំពង់សោមហ្នឹង ។

ដានីៈ ដល់ពេលក្រោយមកបានគាត់ដាក់ទៅកងពល១៦៤?

សុខៈ បាទ ។

ដានីៈ ១៦៤ហ្នឹងបែក៧៥ហើយបានមានកងពលហ្នឹង?

សុខៈ បាទ ។

ដានីៈ ចឹងកាលពូនៅកំពង់សោមហ្នឹងពូនៅកងហាកងវរយុទ្ធវរៈសេនាធំណាទៅ?

សុខៈ កាលជំនាន់ហ្នឹងខ្ញុំជាយុទ្ធជន ។

ដានីៈ តែយុទ្ធជនក្នុងកងណាទៅ?

សុខៈ នៅកងវរៈសេនាតូច១៦២ ។

ដានីៈ កង១៦២ហ្នឹងមានពីណាជាប្រធាន?

សុខៈ មានតា ឈឿន ។

ដានីៈ ចឹងមានដឹងថាសព្វថ្ងៃគាត់នៅណាទេ?

សុខៈ មិនដឹងទេ សព្វថ្ងៃបែកគ្នាអស់ទៅហើយ ។

ដានីៈ ចឹងកងវរៈសេនាធំ?

សុខៈ កងវរៈសេនាធំ តា យាមគាត់ប្រធាន ។

ដានីៈ ឥឡូវគាត់នៅណាដែរ?

សុខៈ ឥឡូវគាត់នៅព្រំដែន ខាងសំឡូត ។

ដានីៈ សំឡូតហ្នឹងគាត់នៅភូមិអីដែរ?

សុខៈ ភូមិគាត់នៅសំឡូតហ្នឹង គាត់ដូចជាលែងនៅហើយ ។

ដានីៈ គាត់នៅណាវិញ?

សុខៈ គាត់ទៅនៅខាងប៉ៃលិនវិញហើយ ។

ដានីៈ ស្រុកកំណើតគាត់នៅណាវិញ?

សុខៈ ស្រុកគាត់នៅនេះ ខ្ញុំមិនសូវដឹងច្បាស់ទេ ខ្ញុំដឹងតែតា ពុត តា សេងទេ ។

ដានី៖	តែតាសេនគាត់ស្លាប់ហើយ?

សុខ៖	ស្លាប់ហើយ ។

ដានី៖	ចឹងកាលហ្នឹងវរៈសេនាធំតា យាម?

សុខ៖	បាទ ។

ដានី៖	ចឹងកាលហ្នឹងចុះទៅកប៉ាល់តែម្តងឬមួយក៏បានហាត់រៀនដែរ?

សុខ៖	អត់មានបានហាត់រៀនអីទេ ដល់ឆ្នាំ៧៦បានហាត់រីករីន ។

ដានី៖	ហាត់រីករីននៅណា?

សុខ៖	នៅដំណាក់ស្តេចមួយកន្លែងចេញពីហ្នឹងទៅ ទៅនៅកោះសេះ ។

ដានី៖	ចឹងគេឲ្យមករៀនសូត្រនៅដំណាក់ស្តេចអូរឈើទាលហ្នឹង?

សុខ៖	បាទ ។

ដានី៖	ពីណាគេមកបង្រៀនយើង?

សុខ៖	មានចិន ។

ដានី៖	រៀនបានរយៈពេលប៉ុន្មាន?

សុខ៖	រៀនបានរយៈពេល៣ខែ ៣ខែហ្នឹងយើងអាចយកទៅប្រើប្រាស់បានហើយណាស់ ។

ដានី៖	បានបីខែចុះទៅណាទៀតទៅ?

សុខ៖	ចុះទៅកប៉ាល់នាវាបណ្តែត ។

ដានី៖	នាវាបណ្តែតហ្នឹងមានគ្នាប៉ុន្មាននាក់?

សុខ៖	មានតែ១២នាក់ ។

ដានី៖	នាវាបណ្តែតមានតួនាទីធ្វើអីទៅ?

សុខ៖	មានតួនាទីបាញ់បុក មីន នាវាហ្នឹងគ្រាន់តែខទាហរណ៍ដល់ខ្សែត្រៀមប្រយុទ្ធ កប៉ាល់ហ្នឹងមានតួនាទីធំជាងគេហើយខាងបាញ់កម្ទេចចោល បើបាញ់កប៉ាល់វាយរនធម្មតាគេមិនប្រើទេ ព្រោះគ្រាប់វាមួយគ្រាប់អាចចិញ្ចឹមប្រជាជនមួយតំបន់ ។

ដានី៖	ចឹងថ្លៃ?

សុខ៖	ថ្លៃណាស់ ហើយបើនាវានោះបាញ់ហើយអត់មានកប៉ាល់ណាគេចផុតទេ អត់មានរួចទេ ។

ដានី៖ បាញ់ទៅត្រូវតែចាំ?

សុខ៖ ត្រូវតែចាំតែម្តង ព្រោះវាមានម៉ាស៊ីនវានៅក្នុងគ្រាប់៧០០សេះ ពេលយើងបាញ់គឺបចឹងគ្រាប់ហ្នឹងរត់ហើយដេញទាល់តែត្រូវកប៉ាល់ហ្នឹងបានផ្ទុះតែម្តង ។

ដានី៖ ចឹងទាល់ប៉ះបានផ្ទុះ?

សុខ៖ បាទ!ទាល់ប៉ះបានផ្ទុះ បើគ្រាប់ហ្នឹងអត់ផ្ទុះធ្លាក់ទៅក្នុងដី កន្លែងហ្នឹងគេត្រូវចំណាំទុកលែងមាននាវាណាហ៊ានបរលើហ្នឹងទៀតទេ ។

ដានី៖ ចឹងកាលហ្នឹងចិនវាបង្រៀនចឹងតែម្តង?

សុខ៖ បាទ ។

ដានី៖ គ្រាប់ហ្នឹងយកមកពីចិន?

សុខ៖ បាទ ។

ដានី៖ គ្រាប់ហ្នឹងប៉ុន្មានដែរ?

សុខ៖ ប៉ុនគល់ដូងហើយមានប្រវែង៦ម៉ែត្រ ។

ដានី៖ អាហ្នឹងគេដាក់ពីក្រោមកប៉ាល់?

សុខ៖ អត់ទេ គេដាក់នៅចំហៀងកប៉ាល់ ហើយបាញ់មិនមែនចេញតែមួយគ្រាប់ទេ ចុចមួយម្តងចេញទាំងពីរតែម្តង ។

ដានី៖ ចឹងខាងជើងទឹកហ្នឹងមានកប៉ាល់បណ្តែតមានកប៉ាល់ស្អីខ្លះទៅ?

សុខ៖ ចាំមើលណាស់ មាននាវាបណ្តែត នាវាការពារ នាវាប្រឆាំង មាននាវាផ្តាច់មីនមានពីរអាហ្នឹងសើបការណា ។

ដានី៖ ចឹងអាបណ្តែតនិងផ្តាច់មីនខុសគ្នា?

សុខ៖ ដូចគ្នា គ្រាន់តែអត់មានឧបករណ៍អីលើហ្នឹងទេ អាបណ្តាច់មីនហ្នឹងនោះមានតែកាំភ្លើងមួយដើម តែល្បឿនរបស់វាលឿនអស់ទាស់ហើយ ។

ដានី៖ ចឹងអា PCS គេសម្រាប់ធ្វើអី?

សុខ៖ អា PCS គេសម្រាប់បាញ់ផ្សោង ។

ដានី៖ អា PCS ប៉ុន្មាន?

សុខ៖ អា PCS ទទឹង៨ម៉ែត្រ បណ្តោយ១០ម៉ែត្រ ។

ដានី៖ ចឹងកាលហ្នឹងពូហាត់រៀនហើយបានចាប់កប៉ាល់ម៉ាដីគ្រែហ្នឹងឬយ៉ាងម៉េច?

សុខ៖ មុនហ្នឹងខ្ញុំហាត់រៀនផ្នែកបច្ចេកទេស កាលហ្នឹងរំដោះភ្នំពេញហើយខ្ញុំទៅនៅជើងទឹកហ្នឹង បានតែមួយអាទិត្យទេ ចាប់ម៉ាដីគ្រែ ។

ដានី៖ ម៉ាដីគ្រែហ្នឹងយ៉ាងម៉េចបានជាគេចាប់?

សុខ៖ ទេ មិនដឹងដែរ យើងដូចជាចោរព្រៃតែម្តងយើងទៅចាប់គេដោយខុសច្បាប់ ។

ដានី៖ ចឹងយើងចាប់ខុសច្បាប់?

សុខ៖ ចាប់ខុសច្បាប់ កប៉ាល់គេហ្នឹងគេរត់នៅលើផ្លូវអន្តរជាតិរបស់គេ ហើយផ្លូវអន្តរជាតិហ្នឹង វាឃ្លាតពីកោះពោល្វៃប្រហែលជា១០គីឡូ ។

ដានី៖ កាលហ្នឹងពួកក្រុមណាទៅចាប់?

សុខ៖ ពួកក្រុមអា PCS កាលហ្នឹងអត់ទាន់មានយកកប៉ាល់តូចៗទៅចាប់ទេ ហើយកប៉ាល់ តូចៗហ្នឹងក៏អត់ទាន់មានទម្លាក់មកដែរ ។

ដានី៖ កាលពូទៅដែរ?

សុខ៖ កាលហ្នឹងខ្ញុំអត់ទៅទេ ខ្ញុំនៅលើកោះតាង ។

ដានី៖ រួចចឹងយ៉ាងម៉េចទៅចឹង?

សុខ៖ កាលហ្នឹងគេចាប់មកចឹង ក៏គេប្រគល់ភារកិច្ចហ្នឹងឲ្យពួកខ្ញុំឡើងទៅការពារលើកប៉ាល់ហ្នឹង ដោយមិនបានប៉ុន្មានមានយន្តហោះទម្លាក់ ហើយខ្ញុំក៏ចុះមកវិញហើយឡើងទៅលើកោះ ។

ដានី៖ ចុះមនុស្សនៅក្នុងកប៉ាល់ហ្នឹង?

សុខ៖ នៅហ្នឹងយកចេញអស់នៅសល់តែមួយនាក់ទេដែលរកមិនឃើញអ្នកកាន់ខាងទូរលេខហ្នឹង ទាក់ទងគ្នាជាប់ ។

ដានី៖ ចឹងយកចេញអស់នៅសល់តែមួយនាក់?

សុខ៖ នៅសល់មួយនាក់រកមិនឃើញ ។

ដានី៖ ហើយយ៉ាងម៉េចទៀតទៅចឹង?

សុខៈ ដល់ហើយខាងទូរលេខហ្នឹងវាទាក់ទងគ្នាវាជាប់ ដល់ហើយវាដឹងថាយើងអត់មាននៅលើកប៉ាល់ហ្នឹង វាជិះអុបប័រវា កប៉ាល់ចម្បាំងវាមកឃើញហើយ វាជិះអបប័រវាមកឡើងលើកប៉ាល់វា ។

ដានីៈ ពួកណាជិះមក?

សុខៈ ………………….ដល់ក្រោយមកវាមានអី វាដឹងថាយើងអត់នៅអត់អី…… ។

ដានីៈ ចឹងមានមនុស្សដែលយើងយកចេញពីកប៉ាល់ហ្នឹងយើងយកមកដាក់នៅកន្លែងណា?

សុខៈ បញ្ជូលមកលើគោកទាំងអស់ យកមកដាក់នៅដំណាក់ស្ដេចហ្នឹង ។

ដានីៈ ដំណាក់ស្ដេចអូរឈើទាលហ្នឹង?

សុខៈ បាទ! ដល់ហើយវាស្រែកថា បើមិនបញ្ជូនអ្នកនៅក្នុងកប៉ាល់ឲ្យត្រឡប់ទៅវិញទេ កម្ពុជាច្បាស់ជារលាយហើយ ។

ដានីៈ វានិយាយចឹងតែម្ដង?

សុខៈ បាទ! កោះហ្នឹងក៏រលាយដែរ ។

ដានីៈ ដល់ហើយធ្វើម៉េចទៅ?

សុខៈ បញ្ជូនឲ្យទៅវិញទៅ ឲ្យទាំងកប៉ាល់ឲ្យទាំងអី ។

ដានីៈ ចឹងលែងឲ្យទៅវិញ?

សុខៈ បាទ លែងឲ្យទៅវិញ ដល់ហើយវាឡើងលើកប៉ាល់វារួចរាល់អស់ហើយ វាវ៉ៃយើងតាមយន្ដហោះ ។

ដានីៈ រួចហើយយ៉ាងម៉េចទៀតទៅ?

សុខៈ យន្ដហោះហ្នឹងមក ដល់មកចុះបានពីរយន្ដហោះ ចុះនៅលើកោះហ្នឹង ហើយអាពីរនោះទៀតវាគ្រាន់តែផ្លែលមកខ្ញុំបាញ់ធ្លាក់តែម្ដង ខ្ញុំបាញ់ធ្លាក់ហ្នឹងដៃខ្ញុំផ្ទាល់តែម្ដង ។

ដានីៈ យកអីបាញ់កាលហ្នឹង?

សុខៈ កាំភ្លើងរូសេត ។

ដានីៈ រូសេត?

សុខៈ បាទ!រូសេតនឹងអត់មានជើងមានដៃទេ ចងបាញ់ ។

ដានីៈ ម៉េចបានពូបាញ់ កាលនឹង?

សុខៈ ចុះបើខ្ញុំរត់អត់រួចទេ ត្រូវគ្រាប់ ។

ដានីៈ ត្រូវកាលណាកាលនឹង ត្រូវនឹងស្អី?

សុខៈ ត្រូវគ្រាប់ គេបាញ់ទម្លាក់ ហើយមង៉ាងទៀត វាបាញ់ថ្នាំពល ខ្ញុំពលលែងទៅរួចទៀត ពល ក៏ងើបពីអាពលនឹងមក បាញ់ទៀត ។

ដានីៈ ពេលបាញ់នឹង ពូដឹងឃើញធ្លាក់ទេ?

សុខៈ បាទ! បាញ់ប្រើទៅ ដាច់ទៅធ្លាក់ ដាច់មួយព្រះៗ អញ្ចឹងឲ្យបាញ់ទៀត អាមួយធ្លាក់ ប្រហែលជា១០ម៉ែត្រពីភ្នែក ផុតកន្ទើរវាធ្លាក់មកខាងនោះ ។

ដានីៈ ចុះមនុស្សនៅក្នុងនឹង?

សុខៈ អាខ្លះងាប់នៅនឹងខ្លះ ហើយក្រៅពីនឹងវាហែលទៅកាប៉ាល់វា ។ កាប៉ាល់វាហែលទឹកទៅ អូប័រវា ។

ដានីៈ ឡើងត្រង់?

សុខៈ បាទ!

ដានីៈ ចុះពូអត់មានបាញ់អីទៀតទេ?

សុខៈ អានឹងលេងបាញ់ទៀតហើយ ។

ដានីៈ នៅសល់តែពូម្នាក់ឯង រួចយ៉ាងម៉េច?

សុខៈ នៅ ៣- ៤- ១០នាក់ដែរ ប៉ុន្តែអាខ្លះនៅយកតែអាយុវា វាអត់មាន បាញ់ដែរ ពេញ ទឹកពេញដីទាំងអស់ ។

ដានីៈ ចុះខបមាគេចាប់កាប៉ាល់អាម៉ាញ៉េអេនឹង ចាប់រយៈពេលប៉ុន្មានបានមានបាញ់គ្នា?

សុខៈ បានតែម៉ាយប់ ម៉ាថ្ងៃ ។

ដានីៈ ចាប់ម៉ោងប៉ុន្មាន?

សុខៈ ចាប់បាន ប្រហែលម៉ោង៣រសៀល ម៉ោង៧បានយកមកដល់កោះ ។

ដានីៈ ៧ព្រឹក?

សុខៈ ៧យប់ ។

ដានីៈ ៧យប់បានមកដល់កោះ រួចយ៉ាងម៉េចទៅ?

សុខៈ បាទ! យកមកអញ្ចឹងខ្ញុំឡើងទៅលើនឹង ហើយបានខ្ញុំចុះទៅវិញ ពាក់កណ្ដាលយប់បាន ចុះពីលើនឹងវិញ បានព្រលឹមឡើងធ្លាក់ ។

ដានីៈ មនុស្សដែលបញ្ជូនមកៗកន្លែង?

សុខៈ បញ្ជូនមកកំពង់សោមអស់ ។

ដានីៈ បញ្ជូនមកបានរយៈពេលប៉ុន្មានបានបញ្ជូនទៅវិញ?

សុខៈ អត់បានមួយយប់ផង ។

ដានីៈ អញ្ចឹងម៉េចនៅនោះ?

សុខៈ បញ្ជូនមកវិញម៉ង បកមកវិញម៉ង ។

ដានីៈ បញ្ជូនមកទាំងយប់អញ្ចឹង?

សុខៈ បាទ!បញ្ជូនមកទាំងយប់ ។

ដានីៈ អញ្ចឹងដល់ពេលព្រលឹមឡើង វាយកយន្តហោះយកអីមកម៉ង?

សុខៈ បាទ!បាញ់ធ្លាក់ម៉ង វាយគ្នានឹងមកម៉ង ប៉ុនយន្តហោះដូចជាមក ។

ដានីៈ យន្តហោះវាច្រើន ប៉ុន្តែយើងបាញ់ធ្លាក់បានតែ២?

សុខៈ បាទ!បាញ់ធ្លាក់តែ២ទេ ប៉ុនយើងផុស ថាម៉ាកអីក៏មាន ឲ្យទម្លាក់ពេញ ។

ដានីៈ ប៉ុនយើងស្លាប់ច្រើនដែរអត់?

សុខៈ ហ៉ ស្លាប់ច្រើនដែរ ។

ដានីៈ ចុះខាងអាមេរិចកាំង?

សុខៈ ខាងអាមេរិកកាំងអស់ច្រើនដែរណា នៅជប៉ុន៤-៥នាក់ដែរ ហើយអាមុជទឹក ។

ដានីៈ ចុះពួថាបានបាញ់ត្រូវអាមេរិចកាំងមួយដែរ?

សុខៈ អានឹងវាទាហានដកទ័ពគេនឹង វាឡើងយន្តហោះអត់ទាន់ ។

ដានីៈ ឡើងយ៉ាងម៉េច?

សុខៈ វាឡើងអត់ទាន់គេ ដល់ហើយវានៅពួនរូងថ្មនឹង វាពួនស្ងាក់ វាលូកដៃគដៃ ដល់ហើយ អ្នកណាដូចជាដើរលេងតាមស្រុកតាមអី ក្រហែង ចងអីនឹងមកថ្ម ។ ដល់ឃើញភ្ញាក់ ព្រើងនឹងម៉ង ឃើញអាមេរិចកាំងញុកកាំភ្លើងកាណុងទៅ អប់នឹងទ្រូង ឆាប់នៅនឹង ។

ដានីៈ ដល់ពេលបាញ់វាឆាប់ហើយ នៅមើលវាទៀតដែរអត់?

សុខៈ ហ៉ឺ!នៅមើល ដឹងថាវាងាប់ហើយ បានប្រាប់ ។

ដានីៈ គេមានទៅយកខ្មោយអីអត់?

សុខៈ អត់ទេ ។

ដានីៈ ចុះកាំភ្លើងមានយកមកទេ?

សុខៈ កាំភ្លើងអត់មានឃើញមានអី ។

ដានីៈ អត់មានកាំភ្លើងមានអីទេ?

សុខៈ បាទ!

ដានីៈ ចុះកាលនឹងរយៈពេលប៉ុន្មានទៅ រយៈពេលគេវាយគ្នាបាញ់គ្នាទៅ?

សុខៈ អានឹងឈប់វាយគ្នាលើកោះហើយណា ម៉ាអាទិត្យ ។

ដានីៈ ម៉ាអាទិត្យ?

សុខៈ បាទ!រយៈម៉ាអាទិត្យហើយបានមកទៅនឹង មានកាន់មានស្អី ។

ដានីៈ ចុះពូនៅកោះនឹងរយៈពេលប៉ុន្មានដែរ?

សុខៈ ហ៉ឺ!នៅកោះនឹងពិបាកដែរ នៅឆ្នាំ៧៥នៅកោះពស់នឹង ។

ដានីៈ អញ្ចឹងពូអាកន្លែងដែលបាញ់អាមេរិចកាំង បើពូទៅកន្លែងនឹង ពូនៅចាំទេ?

សុខៈ ចាំ ចាំនៅតែចាំ ។

ដានីៈ តែមួយនឹងទេ ឃើញដូចថាបាញ់គ្នាស្លាប់?

សុខៈ បាទ!អានឹងដឹងខ្លួនឯងតែម្ដង ទាន់ដង្ហើមម្ដង ។

ដានីៈ យន្តហោះពូបាញ់ទើបបាន២គ្រឿង?

សុខៈ ធ្លាក់ផ្ទាល់ដៃ ។

ដានីៈ ចុះបន្ទាប់ពីព្រឹត្តិការណ៍ដូចថាចាប់បាញ់គេរួចទៅ ម៉េចទៀតទៅ?

សុខៈ អានឹងអត់មានសកម្មភាពអីអាមេរិកកាំងទេ អត់មានចេះតែរឿងសួរ ប៉ុន្តែដារាយរង
ចេះចាំបានដារឿយៗ ចាប់បានស្រី ។

ដានីៈ ចាប់កាប៉ាល់ខាងណា?

សុខៈ ចាប់កាប៉ាល់ថៃ ។

ដានីៈ ចាប់នឹងយ៉ាងម៉េច?

សុខៈ ចាប់ហើយ ចាប់ៗបានតែចាប់ ហើយបញ្ជូនឲ្យគេ បញ្ជូនមកកងពល បញ្ជូនមកកំពង់ដរ

ដានីៈ នៅពេលដែលគ្នាយើងទៅចាប់ ពួកកាប៉ាល់ថៃ យើងទៅចាប់ ពីណាគេអ្នកចាប់?

សុខៈ បើយើងដេញចាប់ បើថាវាអត់ឈប់ បាញ់ពន្ធិចៗ

ដានីៈ មានអ្នកអត់ឈប់ដែរ?

សុខៈ អត់ទេ! អត់ឈប់ យើងបាញ់គំរាមវា ក៏អត់ឈប់ៗ

ដានីៈ ពួខាងកងពល គេបញ្ជាមក?

សុខៈ បាទ!បញ្ជាមកៗ

ដានីៈ បើថាអត់ឈប់ទេ បាញ់ពន្ធិចៗ

សុខៈ ដល់ពេលគេឈប់ទៅ យើងធ្វើម៉េច?

ដានីៈ ឡើងមក យើងបញ្ជាឲ្យវាបើក បើវាអត់បើក យើងបញ្ជាឲ្យបើកៗ

សុខៈ ប៉ុន្តែមនុស្សក្នុងនឹង យើងអត់ចាប់ទេ?

ដានីៈ អត់ទេៗ

សុខៈ អត់មានចងមានអីទេៗ

ដានីៈ បាទ! ចុះអត់ខ្វាចវាតដៃទេ?

សុខៈ បាទ!

ដានីៈ ចុះអត់ខ្វាចវាតដៃទេ?

សុខៈ យើងអត់ទេ គ្រាន់បញ្ជាវាមកដល់គោក ចង មកដល់ៗ

ដានីៈ បញ្ជាមកគោក មកកន្លែងណា?

សុខៈ មកអត់ទេ នៅកោះដែរណា បញ្ជាមកកោះៗ

ដានីៈ កោះណា?

សុខៈ កោះតាងអញ្ចឹង ពោធិ៍ស្វែងៗ

ដានីៈ បញ្ជាមកដល់កន្លែងកោះនឹងបានចាប់ចង?

សុខៈ បាទ!បានចាប់ចងហើយៗ យើងកាត់កាប៉ាល់នេះ កាប៉ាល់យើងបញ្ជូនមកៗ

ដានីៈ ចងនឹងចងយ៉ាងម៉េច ចងស្លាបសេក?

សុខៈ បាទ!មកចងស្លាបសេកប្រសាយគ្នាទៅៗ

ដានី:	ចង់ប្រសាយគ្នាទៅ?

សុខ:	បាទ!

ដានី:	អ្នកនេសាទនឹង ភាគច្រើនមានស្រីមានអី?

សុខ:	ធម្មតាមានប្រុសៗ ។

ដានី:	សុទ្ធតែថៃ?

សុខ:	បាទ!សុទ្ធតែថៃ យួន ។

ដានី:	ដល់ពេលថៃនឹងចង់ហើយបញ្ជូនមកតាកាប៉ាល់យើង បញ្ជូនមកខាងណាបញ្ជូនមកខាង?

សុខ:	កាប៉ាល់ ម៉ាកងពលយើង គេអនុញ្ញាតិថាឥឡូវទុកប្រើៗ បើអត់ទុកឲ្យប្រើទេ ឲ្យគេអូសលើគោក ។

ដានី:	លើគោកបញ្ជូនមកខាងណា?

សុខ:	ខាងកំពង់សោម ។

ដានី:	ខាងកំពង់សោមកន្លែងណា?

សុខ:	មកខាងកោះស្ដេច ដំណាក់ស្ដេច ។

ដានី:	មិនមែននៅខាងរៀមទេ?

សុខ:	អត់ទេ ប៉ុនកងពលតែមួយ ជួនកាលគេឲ្យយកទៅរៀមទៅ ជួនកាលគេឲ្យវាមកកោះស្ដេចមក ។

ដានី:	ប៉ុន្តែមនុស្សដែលបញ្ជូនមកនឹងៗបញ្ជូនមករៀម ឬមកដំណាក់ស្ដេច?

សុខ:	មករៀម ។

ដានី:	ទាំងមនុស្សទាំងអីនឹង?

សុខ:	បាទ!រៀមនឹងយកមក មិនមែនយកមកសម្លាប់ទេ ឲ្យបាយហូបធម្មតាយើងប្រើ ។

ដានី:	ថៃនឹង?

សុខ:	បាទ!

ដានី:	បញ្ជូនមករៀម?

សុខ:	បាទ!

ដានី:	ចុះកាលជំនាន់នឹងកន្លែងទីបញ្ជាការកាលនឹងនៅខាងរៀម?

សុខៈ នៅកំពង់សោម ។

ដានីៈ ខាងកំពង់សោម?

សុខៈ បាទ!

ដានីៈ ចុះខាងវៀម?

សុខៈ ខាងវៀមមានតែកងពលតូចៗ ។

ដានីៈ តាម៉ុកគាត់នៅណា?

សុខៈ តាម៉ុតនៅខាងជិតផ្សារធំ ។

ដានីៈ ផ្សារធំកំពង់សោម?

សុខៈ បាទ!

ដានីៈ អញ្ចឹងអ្នកនេសាទថៃ ដែលគេចាប់នេះមកនឹងគេឲ្យមកជួយជីកប្រឡាយ?

សុខៈ បាទ!ជីក លើកទំនប់ ។

ដានីៈ គេមានបញ្ជូនទៅណាទៀត?

សុខៈ ហើយគេបញ្ជូន ប៉ុនគេប្រាប់ខ្ញុំថាមិនឲ្យប៉ះពាល់ទេ ព្រោះឲ្យគេធ្វើការនឹងហើយ គេឲ្យបញ្ជូនឲ្យទៅវិញ ។

ដានីៈ ឲ្យបញ្ជូនទៅវិញ?

សុខៈ បញ្ជូនទៅស្រុកវិញ ។

ដានីៈ ប៉ុនពូបញ្ជូន ពេលពូបញ្ជូនមកដល់វៀមហើយ ពូបញ្ជូនទៅណាទៀត?

សុខៈ ខ្ញុំបញ្ជូនមកត្រឹមនឹង ប្រគល់ឲ្យគេត្រឹមនឹង ហើយត្រឡប់ទៅវិញ ។

ដានីៈ ដល់ពេលប្រគល់ឲ្យគេ គេយកទៅណា?

សុខៈ គេយកមកខ្លះគេឲ្យលើកទំនប់អីចឹង ខ្ញុំមកឃើញដែលតើ ។

ដានីៈ ជនជាតិថៃហ្នឹង?

សុខៈ បាទ ។

ដានីៈ ឆ្នាំណាដែលពូបានឃើញហ្នឹង?

សុខៈ ឆ្នាំ៧៥ - ៧៦ហ្នឹង ។

ដានីៈ ពេលម៉ាជីគ្រែរួច?

សុខៈ	រួច ។

ដានីៈ	ចឹងឆ្នាំ៧៧-៧៨អី?

សុខៈ	ឆ្នាំ៧៧ខ្ញុំនៅរីករីនហើយ មករៀនបច្ចេកទេស ។

ដានីៈ	រីករីននៅណា?

សុខៈ	រីករីននៅដំណាក់ស្ដេច ។

ដានីៈ	ឆ្នាំ៧០ប៉ុន្មាន?

សុខៈ	ឆ្នាំ៧៦ ។

ដានីៈ	ចឹងពេលចប់រីករីនហើយទៅនៅណាទៀត?

សុខៈ	ពេលរីករីនហើយទៅនៅនាវា ។

ដានីៈ	ចឹងកាលហ្នឹងមានចាប់បានអីទៀតទេ?

សុខៈ	អត់មានចាប់បានអីទៀតទេ ។

ដានីៈ	ចឹងបើចាប់បានពួកយួននោះ?

សុខៈ	បើពួកយួនចាប់បានគេយកមកសម្លាប់ចោល ។

ដានីៈ	សម្លាប់នៅណា?

សុខៈ	ជួនកាលគេសម្លាប់នៅលើកោះហ្នឹងទៅ ។

ដានីៈ	គេអត់មានបញ្ជូនមកខាងទេ?

សុខៈ	ជួនកាលគេសម្លាប់នៅកោះ ។

ដានីៈ	អាហ្នឹងច្រើនពួកកងទ័ពឬមួយយ៉ាងម៉េច?

សុខៈ	ច្រើនតែប្រជាជនដែលរត់ភៀសខ្លួនទៅប្រទេសទីបី គាត់ច្រើនពួកហ្នឹងរត់គេចពីសង្គ្រាម ដល់រត់ឆ្លងមកយើងចាប់បានបាញ់សម្លាប់ចោលទៅ ។

ដានីៈ	ចឹងចាប់បានបញ្ជាពីកងពលទៅឬមួយធ្វើដោយខ្លួនឯង?

សុខៈ	បញ្ជាពីកងពលទៅ ។

ដានីៈ	បញ្ជាចេញពីនរណាទៅ?

សុខៈ	បញ្ជាចេញពីតា មុត ។

ដានីៈ	បញ្ជាឲ្យសម្លាប់តែម្ដង?

សុខៈ បាទ ។

ដានីៈ ចឹងមានគេបញ្ជូនមកដីគោកដែលឬអត់?

សុខៈ មានបញ្ជូនមក ។

ដានីៈ ចឹងច្រើនមានសម្រាប់ផងបញ្ជូនមកផង?

សុខៈ ច្រើន ។

ដានីៈ ចឹងកាលហ្នឹងពូមានឃើញជនជាតិស្បែកសរអីគេចាប់មកបន្ទាប់ពីចាប់កប៉ាល់ម៉ាដីគ្រែ ហើយទេ?

សុខៈ ជួបប្រទះតែជនជាតិអាមេរិចកាំងម្នាក់ដែរ................ ។

ដានីៈ ចាប់កាលឆ្នាំណា?

សុខៈ ចាប់កាលឆ្នាំ៧៦ ។

ដានីៈ កាលហ្នឹងពូមកពីរឹករឹនហើយឬនៅ?

សុខៈ ចាប់ហ្នឹងហើយខ្ញុំមករឹករឹន ។

ដានីៈ អាមេរិចកាំងហ្នឹងស្លៀកពាក់យ៉ាងម៉េច?

សុខៈ ស្លៀកពាក់ធម្មតាហ្នឹង ។

ដានីៈ ចឹងអាវ?

សុខៈ ជួនកាលពាក់អាវឃឹតវាលក្លៀក ។

ដានីៈ ចឹងសក់វាពណ៌អី?

សុខៈ សក់វាពណ៌ក្រហម ។

ដានីៈ សួរវាអាយុប៉ុន្មាន?

សុខៈ សួរវាទៅអាយុប្រហែលជា២៥អីហ្នឹង អត់មានអីលើសពីហ្នឹងទេ ។

ដានីៈ ចឹងវាចេះនិយាយខ្មែរដែរ?

សុខៈ វាចេះមួយម៉ាត់ដែរ តែមានអ្នកបកប្រែអង់គ្លេសដែរ ។

ដានីៈ ចឹងកាលហ្នឹងអាមេរិចកាំងហ្នឹងវាជិះអីមក?

សុខៈ ជិះកាណូតវាមក តែកាណូតវាដូចផ្ទះថ្មចឹង ដងក្តោងវាមានកំពស់ប្រហែលជាចុង ត្នោត ។

ដានី:	មានតែម្នាក់ទេ?

សុខ:	បាទ ។

ដានី:	ចឹងកាលមកពីណា?

សុខ:	កាលហ្នឹងចាប់មកពីកោះពោល្វៃ ។

ដានី:	ចឹងចាប់ហ្នឹងប្រហែលជាចុង៧៦ឬយ៉ាងម៉េច?

សុខ:	ដើមឆ្នាំ៧៦ ។

ដានី:	ចាប់ពីកោះពោល្វៃហ្នឹងហើយបញ្ជូនមកកន្លែងណា?

សុខ:	បញ្ជូនមករៀម  បញ្ជូនទាំណងទូកទាំងមនុស្ស ។

ដានី:	ពេលមកដល់រៀមហើយយ៉ាងម៉េចទៀត?

សុខ:	មកដល់រៀមហើយឲ្យទៅខាងកងពលមិនដឹងគេយកទៅណាខ្ញុំមិនបានដឹកទេ ។

ដានី:	ចឹងក្រៅពីអាមេរិចកាំងម្នាក់ហ្នឹងហើយពីណាទៀត?

សុខ:	អត់ទេ ។

ដានី:	ចឹងឆ្នាំ៧៧និង៧៨អីនោះ?

សុខ:	ឆ្នាំ៧៧-៧៨ហ្នឹងអត់មានចាប់ទេ ។

ដានី:	ចឹងមានដែលចាប់ទូកថៃអីទេ?

សុខ:	មានចាប់ទូកថៃអា៥០០សេះ  អា៤០០សេះ  អា៨០០សេះ ។

ដានី:	ចាប់យកមកដាក់នៅណា?

សុខ:	ចាប់យកមកដាក់លើកោះ ។

ដានី:	ចុះមនុស្ស?

សុខ:	មនុស្សបញ្ជូនយកមកដីគោកខាងរៀមនេះ ។

ដានី:	រួចហើយយកមកខាងណាទៀត?

សុខ:	ខ្លះថាបញ្ជូនមកដីគោកហើយគេបញ្ជូនទៅតាមកោះកុងវិញ ។

ដានី:	តែគេមានធ្វើអីទេ?

សុខ:	អត់មានធ្វើអីទេ ។

ដានី:	តែមានគេបងទេ?

សុខៈ ចង បើជាយួនគេបញ្ជាមកឲ្យវ៉ៃចោល ។

ដានីៈ ចឹងតា មុតមានចុះទៅកន្លែងកប៉ាល់ម៉ាជីគ្រែដែលឬអត់?

សុខៈ អត់មានទៅទេ កប៉ាល់គេចាប់ចឹងគាត់អត់មានទៅជិតដែរ ។

ដានីៈ ចឹងពូស្គាល់តា មុតច្បាស់តែម្តង?

សុខៈ ខ្ញុំជានិរសាររបស់គាត់ ។

ដានីៈ និរសាគាត់តាំងពីឆ្នាំណា?

សុខៈ និរសាគាត់តាំងពីឆ្នាំ៧៨កាលខ្ញុំរត់ហ្នឹង ខ្ញុំជាកងការពារគាត់ផ្ទាល់រហូត ទាល់ផុតពីណុង ទៅគេចាត់តាំងឲ្យខ្ញុំប្រគល់សំបុត្រឆ្លងដែនឲ្យខ្ញុំ ។

ដានីៈ បាទ ។

សុខៈ គាត់ប្រគល់នាទីហ្នឹងឲ្យខ្ញុំ ហើយគ្នាខ្ញុំមាន១២នាក់ ។

ដានីៈ បាទ ។

សុខៈ កងទាហានទាំងអស់មាន៣០ ០ ០ ០នាក់ ......។

ដានីៈ ចឹងតា មុតសព្វគាត់នៅភ្នំពេញឬនៅណា?

សុខៈ តា មុតនេះមិនទៀងនៅសំឡូតទេ អាចនៅប៉ៃលិន.....។

ដានីៈ ចឹងកាលជំនាន់ពូនៅហ្នឹងពូមានដែលឮកោះខ្យងទេ?

សុខៈ កោះខ្យងអីមិនឮ ។

ដានីៈ កោះខ្យងកន្លែងស្អីគេ?

សុខៈ កោះខ្យងកន្លែងកោះធម្មតា កោះខ្យង កោះទន្សាយ ។

ដានីៈ កោះខ្យងហ្នឹងមានកងទ័ពនៅដែរ?

សុខៈ មានតែកងការពារនៅលើកោះហ្នឹង ដល់កោះធំៗ បានគេដឹងហ្នងច្រើនដូចជាកោះរ៉ុង កោះ ព្រីង កោះ តាង កោះពោល្លៃចាស់ កោះពោល្លៃថ្មី ហើយដល់កោះតូចៗ ទៀត អាហ្នឹងគេអត់នៅទេ ដូចជាកោះដូរ កោះថាសអីហ្នឹងគេអត់នៅទេ ។

ដានីៈ ចឹងមានកន្លែងឃុំឃាំង កន្លែងគេចាប់មកដាក់គុកមានដែលអត់?

សុខៈ មានគេចាប់មកដាក់កន្លែងទឹកសាបនៅជិតកោះកេង ខាងកើតវៀម ។

ដានីៈ កន្លែងគេដាក់គុកសម្រាប់ពីណាគេ?

សុខៈ កន្លែងហ្នឹងគេដាក់គុកមិនថាកងទ័ពមិនថាប្រជាជនអីទេ មាននៅខាងត្បូងថ្នល់មួយ ខាងជើងថ្នល់ហ្នឹងមួយ ។

ដានីៈ យ៉ាងម៉េចបានដាពូជីង?

សុខៈ ចុះកាលហ្នឹងគេប្រើឲ្យទៅធ្វើការចុះៗ ធ្វើចឹងស្គាល់ៗគ្នាធ្លាប់ធ្វើការជាមួយគ្នាស្គមដៃដាប់ច្រវ៉ាក់ហើយកាប់ដី ។

ដានីៈ ចឹងពូមានដែលឃើញគេដឹកអ្នកគេចាប់ពីសមុទ្រអីទេឬអ្នកដែលធ្វើជាកងទ័ពជាមួយពូគេយកមកភ្នំពេញអីទេ?

សុខៈ ជាមួយខ្ញុំច្រើនណាស់ ខ្ញុំវាអត់ចេះត កុំអីខ្ញុំងាប់ជាមួយគេហើយ ខ្ញុំអត់ចេះតអីទាំងអស់ហើយកងទ័ពជាមួយគ្នាហ្នឹងអង្គភាពតែមួយហូបបាយជាមួយគ្នាហ្នឹងណាស់អត់មានខុសអីធំដំទេ គ្រាន់តែសួរគ្នាឯងចេះសរសេរពាក្យថា ទមិឡទេ អាមួយថាអីមិនចេះដល់ចេះចឹងគេសរសេរលេងចឹងទៅណាស់ ហើយអាមួយគេសរសេរចេះគេសរសេរគ្រប់គ្នាទៅណាស់ ហើយអត់ចេះតែពីរនាក់ទេ ដល់អស់ហ្នឹងគេចេញហើយចេះតែសរសេរទៅដល់ម៉ោង៧ទៅ៨អង្គរក្សគេមកដល់យប់ឡើងគេចាប់អស់រលីង ។

ដានីៈ កងវរៈពីណាគេ?

សុខៈ កងរបស់តា ឈូក ។

ដានីៈ ឥឡូវគាត់នៅដែរ?

សុខៈ ទេ បាត់អស់ហើយ គេចាប់បាត់ហើយ ។

ដានីៈ ចឹងឆ្នាំណា?

សុខៈ ឆ្នាំ៧៨ហើយ អាអ្នកនៅជាមួយខ្ញុំគេចាប់អស់ហើយវ៉ៃនៅកន្លែងហ្នឹង កាលហ្នឹងបើខ្ញុំចេះនិងគេងាប់បាត់ហើយ បើចូលរួមយកដៃគូសនិងគេងាប់បាត់ហើយ ។

ដានីៈ ទឹកសាបជិតរៀមដែរ?

សុខៈ ឆ្ងាយដែលចាប់មើលចេញពីកងកេងមកទៅកើតទៅតាមថ្នល់ជាតិ ទៅដល់ហ្នឹងមិនមានស្ពានមួយ ស្ពានឆ្លងព្រែកនោះ ។

ដានីៈ ចឹងកាលហ្នឹងពូមានដែលឃើញកងពលអីគេអូទៅហៅពួកមជ្ឈិមទៅយកពីខាងហ្នឹងដែរ?

សុខៈ កាលហ្នឹងតា ឌឹមហ្នឹងនិងតា មុតប្រធានកងពលដូចគ្នា ។

ដានី៖ បាទ ។

សុខ៖ ដល់ហើយចាប់គាត់ទៅ ខ្សែស្រឡាយដែលគាត់អោបទុកហ្នឹងយកមកមួយកន្លែងពលទៅ ។

ដានី៖ យកទៅណា?

សុខ៖ យកមកសម្លាប់ កន្លែងហ្នឹងឡើងចំណោតវៀម វ៉ៃចោលហើយយកអាគ្រាក់មកឈូស ។

ដានី៖ ឆ្នាំណា?

សុខ៖ ឆ្នាំ៧៥ហ្នឹង ។

ដានី៖ ចឹងពេលបែកថ្មីៗហ្នឹង?

សុខ៖ ៧៥បែកហើយថ្មីៗហ្នឹង ៧៥-៧៦ហ្នឹង ។

ដានី៖ ចឹងសម័យតា ឌឹម តា ឡឿនដែរ?

សុខ៖ តា ឡឿនគេទើបចាប់កាល៩៣-៩៤ជាជំនាន់យើងនេះ ។

ដានី៖ តា មុតគាត់ឲ្យចាប់ប្តីយ៉ាងម៉េច?

សុខ៖ បាទ! ខាងលើទៅតា មុត តា មុតគាត់វីសតែងាប់ដែលហ្នឹង គេធ្វើសកម្មភាពគាត់ គាត់មិនបានដឹងអីដែលណា ។

ដានី៖ ចឹងអាមេរិចកាំងម្នាក់ដែលពូថាចាប់បានឆ្នាំ៧៦នោះ ពេលបញ្ជូនមកដីគោកហើយ ពូមានឃើញគេសម្លាប់អីទេ?

សុខ៖ មិនបានឃើញទេ បាត់រហូត.....តែជំនាន់ហ្នឹងអត់មានពីហ៊ានលេងសើចដែរ រឿងរ៉ាវអីក៏អត់មានពីហ៊ាននិយាយសាកសួរដែលកាលហ្នឹង............ ។

ដានី៖ ចឹងឥឡូវពូមានដែលឮរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលឬអត់?

សុខ៖ ប្តីមិនដែលឮ ។

ដានី៖ ចឹងពូយល់ថាយ៉ាងម៉េចដែរ?

សុខ៖ យល់ឃើញថាលើកតែចឹង តែពួកអស់ហ្នឹងនៅតែចឹង ។

ដានី៖ ចឹងបើតាមចិត្តពូ ពូចង់ឲ្យមានតុលាការដែរឬក៏មិនចង់?

សុខ៖ ចង់ ចង់ឲ្យបង្កើតហើយកុំឲ្យមានឃាតករ ។

ដានី៖ ចឹងចង់ឲ្យគេបង្កើតហើយកុំឲ្យមានឃាតករចឹងទៀត?

សុខៈ បាទ!កុំមានគទៅទៀត ។

ដានីៈ ខ្ញុំដូចជាអស់អីសួរពូទៀតហើយខ្ញុំសូមអរគុណពូច្រើន ពូមានចង់បន្ថែមអីតទៀតទេ?

សុខៈ អត់មានទេ បើខ្ញុំមាននិយាយសើលសួលអីកុំប្រកាន់ ខ្ញុំនិយាយការតស៊ូជីវប្រវត្តិដែលធ្លាប់ឆ្លងកាត់ក្នុងសម័យប៉ុល ពត តស៊ូតាំងពីឆ្នាំ៧២រហូតដល់ឆ្នាំ៧៥រំដោះហើយរហូតដល់សម័យសង្គ្រាមចេញពីប៉ុល ពត សម័យប៉ុល ពតនេះខ្ញុំអត់ចេញមកកាលហ្នឹងខ្ញុំមានទំនាស់គ្នា កាលហ្នឹងខ្ញុំធ្វើធំដែលហើយ ។

ដានីៈ ធ្វើធំនៅណា?

សុខៈ នៅខាងសំឡូតដល់ហើយគេមានទំនាស់គ្នា ទំនាស់កាលឆ្នាំ៩២-៩៣ឈប់បាញ់គ្នា ។

ដានីៈ បាទ ។

សុខៈ ដល់ហើយកាលហ្នឹងគេមិនព្រមទៅចរចារមិនព្រមទៅប្រជុំទេ កាលហ្នឹងខ្ញុំមានការស្មុគស្មាញណាស់ កាលជំនាន់ហ្នឹងមានអ៊ុនគាក់ចូលហើយ ។

ដានីៈ បាទ ។

សុខៈ ដល់ចឹងខ្ញុំក៏ដាច់ចិត្តត់មកតែម្តង ។

ដានីៈ កាលហ្នឹងពូធ្វើអីដែរ?

សុខៈ ខ្ញុំទទួលប្រធានកងពិសេសកងពល ។

ដានីៈ កងពិសេសហ្នឹងស្មើរអីដែរ?

សុខៈ ស្មើរនិងកងវរៈសេនាធំ ។

ដានីៈ កងពលលេខប៉ុន្មាន?

សុខៈ កងពលលេខ១៦៨ហ្នឹង ។

ដានីៈ ជាមួយតា មុតនិងដដែល?

សុខៈ អត់ទេ នៅជាមួយតា ម៉េត ។

ដានីៈ ស៊ូ ម៉េតហ្នឹង?

សុខៈ ហ្នឹងហើយ ។

ដានីៈ ចឹងតា ម៉េចប្រធានកងពល ពូប្រធានកងពិសេស?

សុខៈ ខ្ញុំប្រធានកងពិសេស ។

ដានី:	ចឹងកាលហ្នឹងមានការចរចារអីហ្នឹង ពេលមេគេដកខ្លួនទៅពូអន់ចិត្តដែរ?

សុខ:	ខ្ញុំអន់ចិត្ត ខ្ញុំពិការជើងហើយម្យ៉ាងទៀតសង្គ្រាមបេះតែនៅបន្តហើយគេមិនព្រមចរចារគ្នា ដល់ក្រោយមកវិញខ្ញុំទៅលេងផ្ទះទៅលេងនៅហ្នឹង ។

ដានី:	បាទ ។

សុខ:	ពេលចរចារគ្នាហើយបានប្រហែលជាមួយខែបានខ្ញុំទៅ គេបន្ទោសខ្ញុំដែលគេថាមិត្តឯងមានស្តាយក្រោយទេ មិត្តឯងប្រញាប់ទៅពេក ខ្ញុំថាមកពីលោកឯងអស់រាល់គ្នានិងហើយចបេះក្បាលរឹងជៀសចូលទៅមិនរួច ខ្ញុំថាចឹងដែរ ។

ដានី:	ចឹងគេមានថាឲ្យពូយ៉ាងម៉េចវិញ?

សុខ:	គេថានិងហើយលោកឯងប្រញាប់ទៅពេក អត់បានទទួលផលប្រយោជន៍ចឹង ខ្ញុំថានិងហើយមកពីអស់ឯងគ្រប់គ្នាដែលនៅប្រឆាំងនៅតវ៉ា នៅដណ្តើមគ្នាហ្នឹង ។

ដានី:	ដណ្តើមគ្នានិងដណ្តើមយ៉ាងម៉េច?

សុខ:	ដណ្តើមអំណាចគ្នា អ្នកណាក៏គេចង់ធ្វើធំ អ្នកនោះគេក៏ចង់ធ្វើធំនៅចង់តែឈ្លសគ្នាច្បាំងគ្នាហ្នឹង បើចុះចូលរួមគ្នាចឹងមកអ្នកឯងសិទ្ធប៉ុណ្ណានៅតែប៉ុណ្ណឹងដដែលមិនទៅជាចឹងអីនៅចង់មានមុខមានមាត់ ។

ដានី:	ចឹងពូគិតថាសង្គ្រាមកើតឡើងនៅស្រុកខ្មែរសុទ្ធតែចង់កាន់អំណាចរៀងខ្លួនឬមួយយ៉ាងម៉េច?

សុខ:	សង្គ្រាមនេះកើតឡើងពីមុនមកខ្ញុំមិនហ៊ានប៉ាន់ស្មានទេ កាលហ្នឹងគេបំផុសបំផលចឹងមកពីមុនខ្ញុំមិនបានយល់មិនបានដឹងអីដែរ តែយើងឃើញជាក់ស្តែងទៅវាមានវណ្ណៈសក្តិភូមិវណ្ណៈនាយទន់ វណ្ណៈជិះជាន់គេ វណ្ណៈត្រូវគេជិះជាន់ចឹងទៅ ។

ដានី:	បាទ ។

សុខ:	ដល់ចឹងទៅខ្ញុំចូលទៅធ្វើការ ដល់រៀនសូត្រទៅតាមឯកសារគេលើកឡើងចឹងទៅ ដល់ហើយយើងនៅក្រោមគេចឹង យើងនៅខិនឲ្យគេធ្វើបាបឬអី កុំគេធ្វើបាបចេញទៅតស៊ូទៅ នៅសម័យរដ្ឋប្រហារសម្តេចសីហនុអីហ្នឹង ហើយស្រែកឲ្យកូនចៅរួបរួមគ្នាចូលព្រៃដើម្បីតស៊ូទៅ ក៏បែកទៅតាមនិងទៅ ។

ដានី:	ចឹងយ៉ាងម៉េចបានជាពូចេញពីតា មុតទៅនៅជាមួយតា ម៉េតវិញ?

សុខៈ កាលហ្នឹងយើងចេញពីជើងទឹក យើងចូលទៅថៃដល់ចេញពីថៃមកវិញ បើនិយាយពីប្រវត្តិហ្នឹងវាច្រើនណាស់ និយាយមួយថ្ងៃនិងមិនអស់ទេ ។

ដានីៈ ចឹងស្គាល់គា ម៉េតច្បាស់ដែរ?

សុខៈ ច្បាស់ ខ្ញុំចេញពីនេះទៅនាំប្រជាជនទៅដល់ស្រុកថៃនិងហើយ មានទូតមកទទួលទៀត ។

ដានីៈ មានទូតខាងណា?

សុខៈ ទូតខាងខ្មែរក្រហមណាស់ ទូតយកពួកខ្ញុំ១២នាក់ ។

ដានីៈ ទូតខ្មែរក្រហមនៅណា?

សុខៈ ទូតខ្មែរក្រហមប្រចាំនៅស្រុកថៃនិងតែម្តង យកខ្ញុំចេញយកតែ១២នាក់ហ្នឹងក្រុមកងពិសេសដល់យកចេញមក ខ្ញុំចេញមកវិញកាន់កាំភ្លើងទៅ មុនដំបូងដឹកអង្ករយកឲ្យហូបដល់ហើយដាច់អង្ករហ្នឹងទៅអត់អីហូប ខ្ញុំក៏ចូលទៅប្រទេសថៃ ។

ដានីៈ ចឹងកាលហ្នឹងថៃវាឲ្យចូលដែរ?

សុខៈ បាទ! កាលហ្នឹងទូតគេយកទៅហ្នឹងដាក់ក្នុងបន្ទាយគេចឹងគេយកពួកខ្ញុំ១២នាក់ដាក់ចឹងឲ្យទាក់ទងគ្នាចុះឡើងៗដល់គេឈប់ដឹកអង្ករអីមកខ្ញុំចូលធ្វើទាហាននៅហ្នឹងហ្នង ធ្វើបាន៣ខែដាច់ ហើយកាលហ្នឹងគេប្រមូលទៅខ្លែម មានប្រជាជនភៀសខ្លួនហើយមានអង្ករអីគេឲ្យហូបហើយ ។

ដានីៈ ចឹងកាលហ្នឹងពូនៅហ្នឹងឆ្នាំណាឆ្នាំ៨៥?

សុខៈ បាទ ។

ដានីៈ កាលហ្នឹងយ៉ាងម៉េចបានដាច់ជើង?

សុខៈ ដើរឆ្លងស្ពានជាន់មីន ។

ដានីៈ មីនខាងណា?

សុខៈ មីនខាងខ្មែរក្រហមគ្នាឯងដាក់ពេញទឹកពេញដីហ្នឹង កងគេនៅខាងកោះធំអ្នកដាក់ហើយ យើងខាងសំឡូតយើងមិនដឹង ។

ដានីៈ ដាច់កាលឆ្នាំ៨៥?

សុខៈ បាទ!ឆ្នាំ៨៥ ។

ដានីៈ ចឹងខ្ញុំអរគុណពូច្រើន ។

សុខៈ          ប្រាទ ។

**ចប់**